# [វេទិកាសិទ្ធិមនុស្សនៅទីខេត្តព្រះវិហារ ត្រូវផ្អាកពាក់កណ្ដាលទី ខណៈអភិបាលរងខេត្តចោទថា ជាវេទិកាបំរើនយោបាយ]

ដោយ ម៉ម មុនីរតន៍ ថ្ងៃអង្គារ ទី31 ឧសភា ឆ្នាំ2011 ម៉ោង16:06

វេទិកាមជ្ឈមណ្ឌលសិទ្ធិមនុស្ស ដែលបើកឲ្យពលរដ្ឋ និងតំណាងរាស្ត្រ មកពីគ្រប់គណបក្សនយោបាយ មានឱកាសដើម្បីបានជជែកដេញដោល ដែលធ្វើឡើងនៅស្រុករវៀង ខេត្តព្រះវិហារ នៅថ្ងៃអង្គារនេះ ត្រូវបានរំសាយទៅវិញ នៅពាក់កណ្ដាលទី ខណៈដែលអភិបាលខេត្តរង បានចោទប្រកាន់ វេទិកាសិទ្ធិមនុស្សនេះថា ជាវេទិកាបំរើឲ្យគណបក្សនយោបាយ។

លោកស្រី ខូយ ប៊ុនថាន អភិបាលរងខេត្តព្រះវិហារ មានប្រសាសន៍ចោទប្រកាន់ វេទិកាសិទ្ធិមនុស្សនេះថា អ្នកសម្របសម្រួលកម្មវិធី បើកឱកាសឲ្យតំណាងគណបក្សនយោបាយ មកពីគណបក្សមួយចំនួន ដែលបានចូលរួមនោះ មានពេលវេលាវាយប្រហារខ្លាំងៗ មកលើរដ្ឋាភិបាលទៅវិញ ៖ *"អញ្ចឹងបានជាអស់លោកតំណាងរាស្ត្រមួយចំនួន គាត់និយាយតែរឿងនយោបាយ តើអ្នកសម្របសម្រួលខាងសិទ្ធិមនុស្សហ្នឹង បើកពេលអោយនិយាយខ្លាំងម្ល៉េះ ហើយខ្ញុំស្ដាប់ទៅ វាអត់មានពាក់ព័ន្ធ នឹងការងារដែលឆ្លើយទៅប្រជាជនវិញ ខ្ញុំមិនទាមទារម៉ោង ទាមទារពេលអីទេ ប៉ុន្តែអានីសមិនមែនវេទិកានយោបាយ បើវេទិកានយោបាយ យើងអោយច្បាប់ជាវេទិកានយោបាយ អានេះវេទិកាស្ដីពីកង្វល់ប្រជាជន ទៅនិយាយរឿងផ្សេង ដល់អញ្ចឹងខ្ញុំអត់ចេះធ្វើការជាមួយ"* ។

ក៏ប៉ុន្តែលោក ឈឹម សារុធ មន្ត្រីសម្របសម្រួល នៃមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា មានប្រសាសន៍ថា វេទិកាសិទ្ធិមនុស្ស ដែលរៀបចំឡើងនៅពេលនេះ ក្នុងបំណងតែមួយគត់ គឺដើម្បីផ្ដល់ឱកាស ឲ្យពលរដ្ឋ បានជួបតំណាងរាស្ត្រ បង្ហាញពីទុក្ខកង្វល់ ដែលពួកគាត់បានជួបប្រទះ ក្នុងសហគមន៍ជាពិសេសពាក់ព័ន្ធនឹងរឿងព្រៃឡង់។ តែលោកថា ត្រូវបានរំសាយទៅវិញ នៅពាក់កណ្ដាលទី ខណៈដែលអភិបាលខេត្តរង បានចោទប្រកាន់ វេទិកាសិទ្ធិមនុស្សនេះថា ជាវេទិកាបំរើឲ្យគណបក្សនយោបាយ ៖ *"អត់ទាន់បាននិយាយបញ្ចប់ផង គាត់មានប្រតិកម្មខ្លាំងតែម្ដង គាត់ថា គាត់ទទួលយកមិនបានអីអញ្ចឹងទៅ ហើយយើងធ្វើកម្មវិធីហ្នឹង អោយពេលវេលាគាត់តិចពេក ត្រូវតែរៀបចំសារថ្មី ព្រោះអ្នកកាន់កម្មវិធីហ្នឹងមិនយុត្តិធម៌អីអញ្ចឹងទៅ អោយគេនិយាយច្រើនអត់ឃាត់ ដល់ពេលខាងគាត់និយាយច្រើនឃាត់ ប៉ុន្តែអត់ទេ មុននឹងដល់ម៉ោងហ្នឹង យើងមានបុគ្គលិកយើងលើកសញ្ញាបង្ហាញថា នៅសល់ពេល៣០វិនាទីអោយគាត់ដឹងមុន ត្រូវបញ្ចប់"* ។

តែទោះជាបែបណា សម្រាប់តំណាងរាស្ត្រគណបក្សសមរង្ស៊ី លោក ជា ប៉ូច ដែល បានចូលរួមក្នុងវេទិកានៅថ្ងៃអង្គារនេះដែរ មានប្រសាសន៍ថា ការពិតគ្រប់តំណាងរាស្ត្រគណបក្សនយោបាយ ដែលបានចូលរួម ផ្ដោតសំខាន់ចំពោះតែដំណោះស្រាយ របស់ពលរដ្ឋតែប៉ុណ្ណោះ ៖ *"គេមិនដែលបានលើកពីគោលនយោបាយរឿងអីទេ ពីព្រោះតំណាងរាស្ត្រទាំងអស់ គ្រាន់តែគាត់លើកពីកង្វល់របស់ប្រជា*

*រាស្ត្រ ដែលលោកត្រូវការអី គឺគាត់នឹងខិតខំជួយតាមលទ្ធភាព ទៅតាមលទ្ធភាពដែលតំណាងរាស្ត្រកំពុងតែធ្វើហ្នឹង"។*

ពលរដ្ឋដែលបានចូលរួមវេទិកា នៅថ្ងៃអង្គារនេះ យ៉ាងហោចណាស់ជាង៦០០នាក់ មកពីខេត្តនៅជុំវិញតំបន់ព្រៃឡង់ ដោយសារពួកគេ ចង់សំដែងមតិពីការបារម្ភបាត់បង់ព្រៃឡង់ដោយការផ្តល់ដី សម្បទាន។

ពលរដ្ឋ ឈ្មោះ យុត ឃីម ជាជនជាតិដើមគួយ ថ្លែងថា តំណាងរាស្ត្រដែលបានចូលរួមនោះ ពុំបានលើកឡើង ពីបញ្ហានយោបាយនោះទេ តែផ្ទុយមកវិញ គឺព្យាយាមស្វែងរកដំណោះស្រាយ ដែលពលរដ្ឋកំពុងប្រឈម និងចំណុចខ្វះខាតរបស់រដ្ឋាភិបាល។

វេទិកាសិទ្ធិមនុស្ស ដែលរៀបចំនៅស្រុករវៀង ខេត្តព្រះវិហារនេះ ត្រូវបានគេដឹងថា ធ្វើឡើងជាការឆ្លើយតប ចំពោះការស្វែងរកដំណោះស្រាយ ជាច្រើនលើកច្រើនសារ របស់ពលរដ្ឋជាង២ម៉ឺនគ្រួសារ ក្នុងខេត្តចំនួន៤ មានព្រះវិហារ កំពង់ធំ ក្រចេះ និង ខេត្តស្ទឹងត្រែង នៅជុំវិញតំបន់ព្រៃឡង់ ដើម្បីស្នើឲ្យរដ្ឋាភិបាលលុបចោលកិច្ចសន្យានានា ដែលបានផ្តល់ដីសម្បទានសេដ្ឋកិច្ច ឲ្យទៅក្រុមហ៊ុន របស់វៀតណាម ឈ្មោះ CRCK PNT និងក្រុមហ៊ុនមួយចំនួនទៀត ដែលពលរដ្ឋ អះអាងថា បានកាប់បំផ្លាញព្រៃធម្មជាតិ ដើម្បីដាំដំណាំកៅស៊ូ ធ្វើឲ្យប៉ះពាល់ជាខ្លាំង មកលើជីវភាពប្រចាំថ្ងៃ របស់សហគមន៍៕